**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ [illegible]

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០០៩*

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ជំរាបមក**

## ឯកឧត្តម អភិបាលរាជធានីភ្នំពេញ និងអភិបាលគ្រប់ខេត្ត

**កម្មវត្ថុ** : ស្តីពីការរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២ របស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**យោង** : ប្រកាសលេខ ១២៤៩ ប្រ.ក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីកិច្ចប្រជុំចូលកាន់តំណែង កិច្ចប្រជុំសាមញ្ញលើកទី១ កិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការប្រកាសចូលកាន់តំណែង នៃគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី១ និង ការទទួលខុសត្រូវបន្តនូវសិទ្ធិ និង ការទទួលខុសត្រូវពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបមកឯកឧត្តមជ្រាបថា : ពិនិត្យជារួម ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បានរៀបចំកិច្ចប្រជុំចូលកាន់តំណែង និង កិច្ចប្រជុំសាមញ្ញលើកទី១របស់ខ្លួន បានចប់សព្វគ្រប់ប្រកបដោយជោគជ័យ ។ សម្រាប់កិច្ចប្រជុំសាមញ្ញលើកទី២ របស់ក្រុមប្រឹក្សា នឹងត្រូវរៀបចំឡើងមិនឱ្យមុនម្ភៃប្រាំថ្ងៃ ( **២៥** ) ថ្ងៃ ឬលើសពីសាមសិបប្រាំ ( **៣៥** ) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១ ។

ដើម្បីឱ្យកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រព្រឹត្តទៅស្របតាមគោលការណ៍ បទប្បញ្ញត្តិច្បាប់ និង ដើម្បីឱ្យក្រសួងមហាផ្ទៃមានលទ្ធភាពងាយស្រួលក្នុងការតាមដានលទ្ធផល និងពិនិត្យទៅលើនីត្យានុកូលភាពនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងសូមធ្វើការណែនាំនូវខ្លឹមសារដូចខាងក្រោម :

**១**-អភិបាលរាជធានី ឬអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍មកក្រសួងមហាផ្ទៃ អំពី**កាលបរិច្ឆេទ** និង **វត្តមានសមាជិកក្រុមប្រឹក្សា**ដែលចូលរួម នៃកិច្ចប្រជុំចូលកាន់តំណែង និង កិច្ចប្រជុំសាមញ្ញលើកទី១ របស់ក្រុមប្រឹក្សានីមួយៗ ។

**២**-ក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍អំពី**កាលបរិច្ឆេទ** និង **ទីកន្លែង** ដែលត្រូវរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២នៃក្រុមប្រឹក្សារបស់ខ្លួន មកក្រសួងមហាផ្ទៃ ឱ្យបានមុនដំណើរការនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីមួយៗ ។

**៣**-ក្នុងកិច្ចប្រជុំលើកទី២ ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ នឹងត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវចាត់ឱ្យអភិបាលរាជធានី ខេត្ត ធ្វើរបាយការណ៍អំពីកិច្ចប្រជុំនេះ មកក្រសួងមហាផ្ទៃ ដោយផ្តោតជាសំខាន់ទៅលើខ្លឹមសារដូចខាងក្រោម :

- ចំនួនវត្តមាននៃសមាជិកក្រុមប្រឹក្សា ទិដ្ឋភាពរួមនៃកិច្ចប្រជុំ និងលទ្ធផលនៃការអនុម័តរបស់កិច្ចប្រជុំលើបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

- ក្នុងករណីមានការកែសម្រួល ឬបន្ថែមខ្លឹមសារទៅលើគំរូបទបញ្ជាផ្ទៃក្នុង ដែលត្រូវបានរៀបចំដោយក្រសួងមហាផ្ទៃ អភិបាលរាជធានី ឬ អភិបាលខេត្ត ត្រូវធ្វើរបាយការណ៍ជាក់ស្តែងទៅលើខ្លឹមសារដែលបានកែសម្រួល ឬបន្ថែមនោះ រួចផ្ញើមកក្រសួងមហាផ្ទៃ ដើម្បីក្រសួងពិនិត្យទៅលើនីត្យានុកូលភាពនៃបទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាបានអនុម័តរួចហើយនោះ។

៤.ចំពោះកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ឬអភិបាលខេត្ត ត្រូវធ្វើធ្វើការណែនាំដល់អភិបាលក្រុង ស្រុក ខណ្ឌ ធ្វើរបាយការណ៍បូកសរុបអំពីលទ្ធផលនៃកិច្ចប្រជុំសាមញ្ញលើកទី២នៃក្រុមប្រឹក្សារបស់ខ្លួន ដូចដែលបានរៀបរាប់នៅក្នុងចំណុច**ទី១ ទី២** និង**ទី៣** ផ្ញើមកសាលារាជធានី សាលាខេត្ត យ៉ាងយូរបី (០៣) ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ ។

៥.អភិបាលរាជធានី អភិបាលខេត្ត ដោយមានអង្គភាពរដ្ឋបាលមូលដ្ឋានសាលារាជធានី ខេត្ត ជាជំនួយការត្រូវធ្វើការពិនិត្យជាបឋមលើនីត្យានុកូលភាពនៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សានីមួយៗ និងធ្វើការបូកសរុប របាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រភេទនីមួយៗ រួមទាំងឯកសារពាក់ព័ន្ធ ផ្ញើមកក្រសួងមហាផ្ទៃ **យ៉ាងយូរប្រាំពីរ (០៧) ថ្ងៃ** បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌរបស់ខ្លួន បានធ្វើចប់សព្វគ្រប់ ។

ទទួលបានការណែនាំនេះ ប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់ចាត់ចែងផ្សព្វផ្សាយ និង អនុវត្តឱ្យមានប្រសិទ្ធភាព ។

សូមឯកឧត្តម ទទួលនូវសេចក្តីរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ.

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

*(ដើម្បីជូនជ្រាបជាព័ត៌មាន)*

-សាលារាជធានី ខេត្ត

*(ដើម្បីអនុវត្ត និងចម្លងចែកសាលាក្រុង ស្រុក ខណ្ឌ)*

- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលារាជធានី/ខេត្ត.............

# តារាង

## របាយការណ៍អំពីកាលបរិច្ឆេទ ទីកន្លែង និងវត្តមានសមាជិករបស់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ សម្រាប់កិច្ចប្រជុំចូលកាន់តំណែង កិច្ចប្រជុំសាមញ្ញលើកទី១ និង កិច្ចប្រជុំសាមញ្ញលើកទី២

| ល.រ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | កិច្ចប្រជុំចូលកាន់តំណែង | | កិច្ចប្រជុំសាមញ្ញលើកទី១ | | កិច្ចប្រជុំសាមញ្ញលើកទី២ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | កាលបរិច្ឆេទ | សមាជិកវត្តមាន | កាលបរិច្ឆេទ | សមាជិកវត្តមាន | កាលបរិច្ឆេទ | ទីកន្លែង | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |

*ធ្វើនៅ.......................ថ្ងៃទី............ខែ...................ឆ្នាំ ២០០៩*

អភិបាលរាជធានី/ខេត្ត......